01563139

E460/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 02 / 2018
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ៖ | ចៅក្រម **និល ណុន** ប្រធាន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ៖ | ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨ |
| ភាសាដើម៖ | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

## សេចក្តីសម្រេចលើកទីបួន ស្តីពីសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

## ១. ប្រវត្តិនីតិវិធី

១. អនុលោមតាមវិធាន ៣២ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូង តាមគំនិតផ្តួចផ្តើមរបស់ខ្លួន បានចាត់តាំងអ្នកជំនាញពីររូប គឺលោកវេជ្ជបណ្ឌិត Chan Kin Ming និងលោកវេជ្ជបណ្ឌិត ហួត លីនណា ("អ្នកជំនាញ") ឱ្យពិនិត្យជនជាប់ចោទ និងធ្វើរបាយការណ៍ស្តីពីសម្បទារបស់ពួកគេនាពេលបច្ចុប្បន្នក្នុងការចូលរួមសវនាការ [1] ។ ក្រោយពីបានពិនិត្យជនជាប់ចោទ អនុលោមតាមដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង អ្នកជំនាញបានដាក់របាយការណ៍របស់ខ្លួន នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៨[2]។ នៅថ្ងៃដដែលនេះ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជូនសំណៅរបាយការណ៍ទាំងនេះជូនទៅគ្រប់ភាគី ដោយស្នើឱ្យភាគីដាក់នៅត្រឹមថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៨ នូវសំណើណាមួយដែលស្នើសុំធ្វើការដេញដោលអ្នកជំនាញនៅក្នុងសវនាការ អំពីរបាយការណ៍ និងមតិយោបល់របស់ពួកគេ ពាក់ព័ន្ធទៅនឹងសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ [3] ។ ដោយសារថាមិនទទួលបានសំណើណាមួយទេនោះ ទើបមិនមានសវនាការលើបញ្ហានេះឡើយ។

២. អង្គជំនុំជម្រះសាលាដំបូង ធ្លាប់បានសម្រេចចំនួនបីលើក នាពេលកន្លងមកថា ខៀវ សំផន មានសម្បទាក្នុងការចូលរួមសវនាការ[4] ។ សម្រាប់គោលបំណងនៃសេចក្តីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យអ្នកជំនាញធ្វើរបាយការណ៍អំពីព័ត៌មាន ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យដូចបានគូសបញ្ជាក់នៅក្នុងរឿងក្តី *Strugar* ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងអាចសម្រេចថាតើ

---

[1] ដីកាចាត់តាំងអ្នកជំនាញដើម្បីវាយតម្លៃលើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ និងដីកាកំណត់កាលបរិច្ឆេទនៃការវាយតម្លៃ ឯកសារ E460 ("ដីកាបង្គាប់") ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៧។

[2] របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ៖ នួន ជា ឯកសារ E460/2 ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៨។ របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ៖ ខៀវ សំផន ឯកសារ E460/3 ចុះថ្ងៃទី៣០ ខែ មករា ឆ្នាំ ២០១៨ ("របាយការណ៍ស្តីពី ខៀវ សំផន")។ របាយការណ៍ទាំងពីរត្រូវបានចាត់ថ្នាក់ជារបាយការណ៍សម្ងាត់បំផុត។ របាយការណ៍ទាំងនេះបានដាក់ចូលក្នុងសំណុំរឿងជាផ្លូវការនៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៨ ពីព្រោះថា ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ គឺជាថ្ងៃឈប់សម្រាកផ្លូវការរបស់ អ.វ.ត.ក.។

[3] អ៊ីមែលដែលអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនភាគី ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៨។

[4] សេចក្តីសម្រេចលើកទីបី ស្តីពីសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ និងដីកាបង្គាប់ឱ្យធ្វើតេស្តទៅលើបញ្ហាស្មារតីប្រចាំត្រីមាស ឯកសារ E389/6 ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៦។ សេចក្តីសម្រេចលើកទីពីរស្តីពីសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ ឯកសារ E329/8 ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ ("សេចក្តីសម្រេចលើកទីពីរស្តីពីសម្បទា")។ សេចក្តីសម្រេចស្តីពីសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ ឯកសារ E301/12 ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤។

នៅពេលបច្ចុប្បន្ននេះ ជនជាប់ចោទម្នាក់ៗមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការបានដែរ ឬ ទេ[5]។

## ២. <u>កោសល្យវិច័យរបស់អ្នកជំនាញ</u>

៣. អ្នកជំនាញបានពិនិត្យជនជាប់ចោទ ខៀវ សំផន នៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៨ ហើយបានពិនិត្យមើលរបាយការណ៍វេជ្ជសាស្ត្រប្រចាំសប្តាហ៍របស់គ្រូពេទ្យនៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក. និងនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ក្នុងរាជធានីភ្នំពេញ[6]។ នៅក្នុងរបាយការណ៍ចំពោះជនជាប់ចោទ ខៀវ សំផន អ្នកជំនាញបានលើកឡើងថា ជនជាប់ចោទ ខៀវ សំផន មានប្រវត្តិជំងឺរ៉ាំរ៉ៃមួយចំនួន ហើយមានប្រវត្តិចូលសម្រាកនៅក្នុងមន្ទីរពេទ្យញឹកញាប់ដែរ ប៉ុន្តែ បានកត់សម្គាល់ថា ជនជាប់ចោទ ខៀវ សំផន បានជាសះស្បើយទាំងស្រុងពីជំងឺថ្មីៗបំផុត ហើយពុំត្រូវបានបញ្ជូនទៅសម្រាកនៅមន្ទីរពេទ្យទេ ចាប់តាំងពីឆ្នាំ ២០១៧ មក[7]។ អ្នកជំនាញរកឃើញថា ចង្វាក់បេះដូង ភាពស្ពេកស្គាំង ដង្ហើម និងចលនាសាច់ដុំ មានសភាពធម្មតាទាំងអស់[8]។ សម្ពាធឈាម និងចង្វាក់បេះដូងរបស់គាត់កើនឡើងបន្តិច។ អ្នកជំនាញយល់ឃើញថា បញ្ហានេះអាចបណ្តាលមកពីការពិនិត្យកាយសម្បទាគាត់ក្រោយពេលធ្វើសម្ភាសគាត់រួច ដែលក្នុងអំឡុងពេលសម្ភាសន៍នេះ គាត់មានការប៉ះពាល់ផ្លូវចិត្តខ្លះ[9]។

៤. នៅក្នុងអំឡុងពេលសម្ភាសជាមួយអ្នកជំនាញ ជនជាប់ចោទ ខៀវ សំផន និយាយខ្លាំងៗក្នុងប្រយោគបន្តជាប់ៗគ្នា ហើយពុំមានការលំបាកក្នុងការស្តាប់សំណួរនោះឡើយ ប្រសិនបើសួរគាត់មួយៗ ហើយឲ្យបានឮខ្លាំងៗនោះ[10]។ ជនជាប់ចោទ ខៀវ សំផន អាចដើរបានដោយពុំមានជំនួយ

---

[5] ដីកាបង្គាប់ កថាខណ្ឌ ៦ *ដកស្រង់ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Strugar* អង្គជំនុំជម្រះតុលាការកំពូលនៃសាលាក្តី ICTY សំណុំរឿង IT-01-42-A សាលដីកា ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨ ("សាលដីកា *Strugar*") កថាខណ្ឌ ៥៥។

[6] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៣, ៥, ៨, ២៧។

[7] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៦-១០។

[8] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ២០។

[9] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ២០។

[10] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ១៨-១៩។

ទប់ ប៉ុន្តែឆាប់ហត់ជាងមុន[11]។ ជាងនេះទៀត ជនជាប់ចោទ ខៀវ សំផន អាចអានបាន ដោយប្រើវ៉ែនតា និងកែវពង្រីក[12]។ គាត់ស្គាល់អ្នកជំនាញ ទោះបីជាមិនអាចចាំឈ្មោះក៏ដោយ[13]។

៥. អ្នកជំនាញរាយការណ៍ថា គ្រូពេទ្យព្យាបាលជនជាប់ចោទ ខៀវ សំផន នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត យល់ឃើញថា សុខភាពរបស់ជនជាប់ចោទ ខៀវ សំផន បានប្រសើរឡើង ហើយកត់សម្គាល់ឃើញថា ពុំមានបញ្ហាសុខភាពជាក់លាក់ណាមួយនោះទេ[14]។ គ្រូពេទ្យព្យាបាលបានលើកឡើងទៀតថា ជនជាប់ចោទ ខៀវ សំផន នៅបន្តហាត់ប្រាណនាពេលល្ងាច អាចដើរបានដោយគ្មានជំនួយទប់ ហើយអាចអាន និងរៀបចំឯកសារនៅលើកុំព្យូទ័ររបស់គាត់បាន[15]។ គ្រូពេទ្យព្យាបាលបានរាយការណ៍ថា មិនមានភស្តុតាងណាមួយឱ្យឃើញថា ជនជាប់ចោទ ខៀវ សំផន មានបញ្ហាការចងចាំ ការផ្ចង់អារម្មណ៍ ឬ អារម្មណ៍ប្រែប្រួលនោះទេ[16]។

៦. អ្នកជំនាញរកឃើញថា ជនជាប់ចោទ ខៀវ សំផន អាចផ្ចង់អារម្មណ៍ពេញលេញក្នុងអំឡុងពេលធ្វើសម្ភាស ៦០ នាទី បង្ហាញឱ្យឃើញថាមានស្មារតីរហ័សរហួន និងបានឆ្លើយតបយ៉ាងច្បាស់ទៅនឹងសំណួរទាំងអស់ដែលបានសួរ [17] ។ អ្នកជំនាញបានរកឃើញភស្តុតាងបង្ហាញច្បាស់ថា ជនជាប់ចោទ ខៀវ សំផន នៅរក្សាបានការចងចាំរយៈពេលយូរ ហើយគាត់ទទួលបានពិន្ទុក្នុងកម្រិតមួយដែលចាត់ទុកថាមានសភាពធម្មតានៅពេលអ្នកជំនាញធ្វើការពិនិត្យស្មារតី[18]។ អ្នកជំនាញបានផ្តល់យោបល់ថា ស្ថានភាពស្មារតីរបស់ជនជាប់ចោទ ខៀវ សំផន មានសភាពធម្មតា ហើយការចងចាំរយៈពេលខ្លី ការផ្ចង់អារម្មណ៍ និងការផ្តោតអារម្មណ៍របស់គាត់ល្អប្រសើរទាំងអស់សម្រាប់វ័យគាត់ [19] ។ អ្នកជំនាញកត់សម្គាល់ឃើញថា ការធ្វើតេស្តស្មារតីជាទៀងទាត់ក្នុងទម្រង់ជាតេស្ត

---

[11] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ១០។

[12] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ១១, ១៩។

[13] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ១៧, ៣១។

[14] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៩។

[15] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ១០-១១។

[16] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ២៨។

[17] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៣០។

[18] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៣១, ៣៣។

[19] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៣៤-៣៥។

សង្ខេបលើស្មារតី (តេស្តខ្លីៗលើស្មារតី) បានធ្វើឡើងរៀងរាល់បីខែម្តងសម្រាប់ជនជាប់ចោទ ខៀវ សំផន ហើយនៅក្នុងគ្រប់តេស្តទាំងអស់ លទ្ធផលពុំបានបង្ហាញឱ្យឃើញថាមានការចុះខ្សោយផ្នែកបញ្ហាស្មារតីនោះទេ[20]។ ជាពិសេស អ្នកជំនាញក៏បានរកឃើញផងដែរថា ជនជាប់ចោទ ខៀវ សំផន មិនមានបញ្ហាផ្លូវចិត្ត ឬ បញ្ហាស្មារតី ដែលប៉ះពាល់ដល់គាត់ក្នុងការប្រើប្រាស់សមត្ថភាពចាំបាច់ ដូចបានគូសបញ្ជាក់នៅក្នុងរឿងក្តី *Strugar*[21]នោះទេ។

៧. អ្នកជំនាញសន្និដ្ឋានថា បច្ចុប្បន្នជនជាប់ចោទ ខៀវ សំផន ពុំមានបញ្ហាសុខភាពផ្លូវកាយដែលប៉ះពាល់ដល់សមត្ថភាពរបស់គាត់ក្នុងការចូលរួមសវនាការនោះឡើយ។ ក៏ប៉ុន្តែ អ្នកជំនាញផ្តល់អនុសាសន៍ឱ្យនិយាយទៅកាន់គាត់ឮៗ ច្បាស់ៗ និងយឺតៗ ហើយផ្តល់ពន្លឺគ្រប់គ្រាន់ និងកែវពង្រីកជូនគាត់ប្រសិនបើតម្រូវឱ្យគាត់អានឯកសារនានា [22] ។ អ្នកជំនាញយល់ឃើញថា កាលវិភាគសវនាការប្រចាំថ្ងៃនាពេលថ្មីៗនេះ នៅពេលព្រឹក និងពេលរសៀលរយៈពេល ២ ម៉ោងកន្លះ រួមជាមួយនឹងរយៈពេលសម្រាក ២ ម៉ោង នៅតែមានលក្ខណៈសមរម្យសម្រាប់ជនជាប់ចោទ ខៀវ សំផន[23]។ ។

៨. អ្នកជំនាញសង្កេតឃើញថា ការចងចាំ និងមុខងារបញ្ញាស្មារតីរបស់ជនជាប់ចោទ ខៀវ សំផន ទំនងជាចុះខ្សោយជាបណ្តើរៗទៅតាមវ័យ ហើយផ្តល់អនុសាសន៍ឱ្យធ្វើការពិនិត្យឡើងវិញជាទៀងទាត់លើមុខងារបញ្ញាស្មារតីរបស់គាត់ ជាពិសេសប្រសិនបើការចងចាំ ឬ បញ្ញាស្មារតីរបស់គាត់ចុះខ្សោយគួរឱ្យកត់សម្គាល់[24]។ អ្នកជំនាញក៏បានផ្តល់អនុសាសន៍ឱ្យតាមដានឱ្យបានជាប់លាប់លើសម្ពាធឈាម និងទម្ងន់របស់ជនជាប់ចោទ ខៀវ សំផន ប៉ុន្តែកត់សម្គាល់ថា បញ្ហានេះពុំគួរប៉ះពាល់ដល់លទ្ធភាពរបស់គាត់ក្នុងការចូលរួមសវនាការនោះទេ[25]។

## ៣. ច្បាប់ជាធរមាន

[20] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ២៨។

[21] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៣៦-៤៧។

[22] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៤ នៃផ្នែកសេចក្តីសន្និដ្ឋាន។

[23] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៣ នៃផ្នែកសេចក្តីសន្និដ្ឋាន។

[24] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៤៨។

[25] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ២៥។

៩. ដើម្បីមានសម្បទាក្នុងការចូលរួមសវនាការបាន ជនជាប់ចោទត្រូវមានសមត្ថភាពចូលរួមប្រកបដោយអត្ថន័យដែលអាចឲ្យគាត់អនុវត្តសិទ្ធិទទួលបានការជំនុំជម្រះលើរូបគាត់ ប្រកបដោយយុត្តិធម៌ ក្នុងកម្រិតមួយដែលថា គាត់មានលទ្ធភាពចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងការជំនុំជម្រះលើរូបគាត់ ហើយគាត់យល់ចំណុចសំខាន់ៗនៃកិច្ចដំណើរការនីតិវិធី[26]។

## ៤. សំអាងហេតុ

១០. នៅពេលធ្វើការវាយតម្លៃនេះ អង្គជំនុំជម្រះសាលាដំបូងពិចារណាលើកត្តាពាក់ព័ន្ធទាំងអស់ រួមទាំងភ័ស្តុតាងពីអ្នកជំនាញ សេចក្តីសង្កេតផ្ទាល់របស់ខ្លួន ផលប៉ះពាល់ដោយសារស្ថានភាពសុខភាពរបស់ជនជាប់ចោទ អត្ថិភាពនៃវិធានការជាក់ស្តែងក្នុងការកាត់បន្ថយផលប៉ះពាល់ដោយសារការចុះខ្សោយសុខភាព ហើយថា ជនជាប់ចោទត្រូវបានតំណាងដោយមេធាវីដែលមានសមត្ថភាព និងផ្តល់ប្រឹក្សាយោបល់។

១១. ក្រោយពីបានពិនិត្យមើលរបាយការណ៍លើជនជាប់ចោទ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ជនជាប់ចោទ ខៀវ សំផន នៅតែមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ហើយបច្ចុប្បន្នពុំមានការចុះខ្សោយផ្នែកស្មារតី ឬ រាងកាយដែលរារាំងគាត់មិនឲ្យបន្តការចូលរួមដំណើរការសំណុំរឿង ០០២/០២ នោះទេ។

១២. អង្គជំនុំជម្រះកត់សម្គាល់លើអនុសាសន៍របស់អ្នកជំនាញ ដែលណែនាំឲ្យមានការពិនិត្យជាទៀងទាត់លើមុខងារបញ្ញាស្មារតីរបស់ជនជាប់ចោទ ខៀវ សំផន ហើយរំឭកថា នៅថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០១៧ អង្គជំនុំជម្រះបានបង្គាប់ឲ្យបន្តធ្វើតេស្តមុខងារបញ្ញាស្មារតីរបស់គាត់រៀងរាល់ត្រីមាស រហូតដល់ខែ មិថុនា ឆ្នាំ ២០១៨ គឺត្រូវធ្វើឡើងដោយគ្រូពេទ្យវិជ្ជាជីវៈដែលទទួលកិច្ចសន្យាផ្តល់សេវាជូនអង្គភាពមន្ទីរឃុំឃាំងនៃ អ.វ.ត.ក. ("អង្គភាពសេវាសុខភាព")[27]។

---

[26] រឿងក្តី *Strugar* កថាខណ្ឌ ៥៥។

[27] ដីកាបង្គាប់ឲ្យធ្វើតេស្តទៅលើសតិបញ្ញាស្មារតីរបស់ នួន ជា និង ខៀវ សំផន ប្រចាំត្រីមាស ឯកសារ E329/9 ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០១៥។ ដីកាបង្គាប់ឲ្យធ្វើតេស្តទៅលើសតិបញ្ញាស្មារតីរបស់ នួន ជា និង ខៀវ សំផន ប្រចាំត្រីមាស - សេចក្តីបញ្ជាក់ ឯកសារ E329/9.1 ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥។ ដីកាបង្គាប់ឲ្យកំណត់ពេលវេលានៃការធ្វើតេស្តទៅលើសតិបញ្ញាស្មារតីរបស់ជនជាប់ចោទ ឯកសារ E329/11 ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥។

**យោងតាមសំអាងហេតុ ដូចបានជម្រាបជូនខាងលើ អង្គជំនុំជម្រះសាលាដំបូង ÷**

**បញ្ជាក់** ថា ជនជាប់ចោទ ខៀវ សំផន មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។

យោងតាមដីកាបង្គាប់ឱ្យធ្វើតេស្តលើបញ្ញាស្មារតីប្រចាំត្រីមាស **បង្គាប់÷**

១. ត្រូវបន្តធ្វើតេស្តមុខងារបញ្ញាស្មារតីរបស់ជនជាប់ចោទ ខៀវ សំផន យ៉ាងហោចណាស់ឱ្យបានម្តងក្នុងមួយត្រីមាស។

២. អ្នកជំនាញដែលបានតែងតាំង ត្រូវរៀបចំតេស្ត ដើម្បីវាយតម្លៃលើមុខងារបញ្ញាស្មារតីរបស់ជនជាប់ចោទ ខៀវ សំផន និងត្រូវធ្វើការងារជាមួយនឹងបុគ្គលិកដែលមានគុណវុឌ្ឍិនៅអង្គភាពសេវាសុខភាពរបស់ អ.វ.ត.ក. ដើម្បីធ្វើតេស្តទាំងនេះ និងធ្វើរបាយការណ៍អំពីលទ្ធផលជូនមកអង្គជំនុំជម្រះសាលាដំបូង និង

**បង្គាប់** ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ យោងតាមដីកាបង្គាប់ឱ្យធ្វើតេស្តលើបញ្ញាស្មារតីប្រចាំត្រីមាស សម្របសម្រួល និងកំណត់កាលវិភាគសម្រាប់ធ្វើតេស្តដែលនៅសេសល់ទាំងអស់ ដោយធ្វើតេស្តបន្ទាប់ពីនេះយ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៨។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE ECCC

និល ណុន